# ប័ណ្ណ Vax សម្រាប់ជំងឺ COVID-19 / សំណួរដែលសួរញឹកញាប់អំពីMyIR Mobile

**តើប័ណ្ណ Vax ជាអ្វី?**

Vax Card (ប័ណ្ណ Vax) គឺជាកំណត់ត្រាផ្លូវការអំពីការចាក់វ៉ាក់សាំង COVID-19 របស់អ្នក។ នៅពេលចាក់វ៉ាក់សាំង អ្នកគួរតែទទួលបានប័ណ្ណមួយពី Center for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) ដែលមានកាលបរិច្ឆេទចាក់វ៉ាក់សាំង COVID-19 របស់អ្នក និងស្លាកយីហោ។ ប្រសិនបើអ្នកមិនទទួលបានប័ណ្ណ ឬអ្នកបាត់បង់វា មានវិធីផ្សេងទៀតដើម្បីបញ្ជាក់ថាអ្នកបានទទួលការចាក់វ៉ាក់សាំង (មើលសំណួរនិងចម្លើយខាងក្រោម)។

**តើមានអ្វីខ្លះដែលចាត់ទុកថាជាកំណត់ត្រាផ្លូវការអំពីការចាក់វ៉ាក់សាំង?**

ខាងក្រោមនេះជាឧទាហរណ៍អំពីកំណត់ត្រាផ្លូវការស្តីពីការចាក់វ៉ាក់សាំង៖

- កំណត់ត្រាចាក់វ៉ាក់សាំងពេញមួយជីវិត/ប័ណ្ណ Vax របស់CDC COVID-19
- ឯកសារបោះពុម្ព Immunization Information System (ប្រព័ន្ធព័ត៌មានអំពីការចាក់វ៉ាក់សាំង) រដ្ឋវ៉ាស៊ីនតោន
- ឯកសារបោះពុម្ព MyIR (ភាសាអង់គ្លេសតែប៉ុណ្ណោះ) (ជារូបភាពអេក្រង់ ឬ លិខិតបញ្ជាក់អំពីការស្ថានភាពចាក់វ៉ាក់សាំង)
- លិខិតបញ្ជាក់អំពីការចាក់វ៉ាក់សាំង COVID-19 My IR Mobile (ភាសាអង់គ្លេសតែប៉ុណ្ណោះ)
- ឯកសារបោះពុម្ពកំណត់ត្រាវេជ្ជសាស្ត្រតាមប្រព័ន្ធអេឡិចត្រូនិកដែលបានផ្ទៀងផ្ទាត់ ពីអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់អ្នក

អ្នកមិនអាចធ្វើប័ណ្ណ Vax ផ្ទាល់ខ្លួនអ្នកបានទេ ដោយសារតែវាមិនត្រូវបានគេទទួលស្គាល់ថាជាកំណត់ត្រាផ្លូវការឡើយ។ កំណត់ត្រាផ្លូវការគឺជាឯកសារវេជ្ជសាស្ត្រដែលបានផ្ទៀងផ្ទាត់ ដែលទទួលបាននៅពេលចាក់វ៉ាក់សាំង តាមរយៈអ្នកផ្តល់សេវាវេជ្ជសាស្ត្រ ឬតាមរយៈប្រព័ន្ធតំណភ្ជាប់កម្មវិធីនៃសេវា MyIR ដែលមានរៀបរាប់ខាងក្រោម។

**តើខ្ញុំគួរតែរក្សាទុកប័ណ្ណ Vax របស់ខ្ញុំដូចម្តេច?**

អ្នកគួរតែរក្សាទុកប័ណ្ណ Vax របស់អ្នកនៅក្នុងទីកន្លែងសុវត្ថិភាព! ចាត់ទុកប័ណ្ណនេប្រៀបដូចជាសំបុត្រកំណើត ឬលិខិតឆ្លងដែនរបស់អ្នកដែរ។ អ្នកអាចថតរូបថតប័ណ្ណនេះ ធ្វើការថតចម្លង អ៊ុតប្លាស្ទិកច្បាប់ចម្លង (ប៉ុន្តែហាមអ៊ុតច្បាប់ដើម) ឬអនុវត្តវិធានការដោយធ្វើយ៉ាងណាត្រូវប្រាកដថាអ្នកមានច្បាប់ចម្លងនៃប័ណ្ណនេះ។

សម្រាប់គន្លឹះបន្ថែមទៀតអំពីការគ្រប់គ្រងឲ្យបានត្រឹមត្រូវលើប័ណ្ណ Vax របស់អ្នក អ្នកអាចផ្តល់ប័ណ្ណនេះទៅដល់គ្រួសារនិងមិត្តភក្តិ។ ចុចនៅទីនេះលើខិត្តប័ណ្ណជាភាសារបស់អ្នក៖ (បច្ចុប្បន្ននេះមានផ្តល់ជូនជា ភាសាអង់គ្លេស និង ភាសាអេស្ប៉ាញ)។

**ហេតុអ្វីបានជាខ្ញុំចាំបាច់ត្រូវរក្សាទុកប័ណ្ណ Vax របស់ខ្ញុំ?**

ប័ណ្ណ Vax របស់អ្នក គឺជាមធ្យោបាយដ៏ងាយស្រួលមួយសម្រាប់អ្នកក្នុងការបង្ហាញភស្តុតាងបញ្ជាក់ថា អ្នកត្រូវបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺ COVID-19។ អ្នកអាចនឹងចាំបាច់ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីការចាក់វ៉ាក់សាំងដើម្បីអាចធ្វើដំណើរ ចូលរួមក្នុងព្រឹត្តិការណ៍នានា និងអាចបន្ថែមព័ត៌មានអំពីដូសវ៉ាក់សាំងបន្ថែមនៅក្នុងពេលអនាគត។

អាជីវកម្មជាច្រើននៅក្នុងរដ្ឋវ៉ាស៊ីនតោន ក៏កំពុងផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់អ្នកដែលផ្តល់ភស្តុតាងបញ្ជាក់ពីការទទួលបានការចាក់វ៉ាក់សាំងគ្រប់ចំនួន។ នេះអាចរួមមានការចុះតម្លៃ របស់ថែម ឬកន្លែងអង្គុយដែលពួកគេពេញចិត្តសម្រាប់ព្រឹត្តិការណ៍ណាមួយ។

**តើខ្ញុំធ្វើដូចម្តេច ប្រសិនបើខ្ញុំមិនបានទទួលបានប័ណ្ណ Vax នៅពេលទទួលវ៉ាក់សាំងរបស់ខ្ញុំ?**

ប្រសិនបើអ្នកមិនទទួលបានប័ណ្ណ Vax នៅពេលអ្នកបានទទួលវ៉ាក់សាំង COVID-19 អ្នកអាចទាក់ទងទៅកាន់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក។ អ្នកក៏អាចចូលទៅកាន់កំណត់ត្រាវ៉ាក់សាំង COVID-19

របស់អ្នកតាមអនឡាញ តាមរយៈ www.MyIRMobile.com (ភាសាអង់គ្លេសតែប៉ុណ្ណោះ) និងបង្កើតគណនី ដោយឥតគិតថ្លៃ។

**តើខ្ញុំធ្វើដូចម្តេច ប្រសិនបើខ្ញុំមិនបានទទួលបានប័ណ្ណ Vax នៅពេលទទួលវ៉ាក់សាំងរបស់ខ្ញុំ?**
ប្រសិនបើអ្នកបាត់បង់ប័ណ្ណ Vax របស់អ្នក អ្នកអាចទទួលបានភស្តុតាងបញ្ជាក់ផ្លូវការអំពីការចាក់វ៉ាក់សាំង COVID-19 តាមរយៈអ្នកផ្តល់សេវាថែទាំសុខភាព ឬតាមរយៈការបង្កើតគណនីនៅលើ www.MyIRMobile.com (ភាសាអង់គ្លេសតែប៉ុណ្ណោះ)។

**តើMyIR Mobileជាអ្វី?**
MyIR Mobile គឺប្រព័ន្ធតំណភ្ជាប់កម្មវិធីតាមប្រព័ន្ធអ៊ីនធឺណិតដែលផ្តល់លទ្ធភាពឲ្យមនុស្សចូលទៅកាន់កំណត់ត្រាចាក់វ៉ាក់សាំងរដ្ឋជាផ្លូវការរបស់អ្នក។ អ្នកអាចបង្កើតគណនី តាមរយៈ www.MyIRMobile.com (ភាសាអង់គ្លេសតែប៉ុណ្ណោះ)។

សូមចងចាំថា MyIR Mobile បច្ចុប្បន្ននេះមានកំណត់ត្រឹមភាសាអង់គ្លេសតែប៉ុណ្ណោះ។ សម្រាប់ជំនួយភាសា ឬជំនួយបន្ថែមទៀតក្នុងការទទួលបានកំណត់ត្រារបស់អ្នក អ្នកអាចទូរសព្ទទៅ Office of Immunization and Child Profile (ការិយាល័យនៃការចាក់ថ្នាំបង្ការនិងប្រវត្តិកុមារ)រដ្ឋវ៉ាស៊ីនតោន ក្នុងម៉ោងធ្វើការធម្មតា តាមរយៈលេខ 236-3595 ឬទាក់ទងតាមអ៊ីម៉ែលតាមរយៈ waiisrecords@doh.wa.gov។

**តើខ្ញុំទទួលបានកំណត់ត្រាចាក់វ៉ាក់សាំង COVID-19 របស់កូនខ្ញុំ?**
កូនរបស់ខ្ញុំគួរបានទទួលប័ណ្ណ Vax របស់CDC ផ្ទាល់ខ្លួនរបស់ពួកគេនៅពេលចាក់វ៉ាក់សាំង។ ជាការប្រសើរ អ្នកគួរតែរក្សាទុកប័ណ្ណនេះដោយសុវត្ថិភាពសម្រាប់ពួកគេដូចគ្នាទៅនឹងរបៀបដែលអ្នករក្សាទុកប័ណ្ណផ្ទាល់ខ្លួនអ្នក។ មើលតារាងជម្រើសការរក្សាទុកខាងលើ។ ជាការល្អ អ្នកគួររក្សាទុកប័ណ្ណនេះដោយសុវត្ថិភាពសម្រាប់ពួកគេ ដូចគ្នាទៅនឹង របៀបដែលអ្នករក្សាទុកប័ណ្ណផ្ទាល់ខ្លួនរបស់អ្នកដែរ។ មើលបញ្ជីរាយនាមជម្រើសរក្សាទុកខាងលើ។

ប្រសិនបើកូនរបស់អ្នកមិនមានប័ណ្ណ Vax របស់ CDCទេនោះអ្នកអាចទទួលបានសេចក្តីចម្លងផ្លូវការមួយច្បាប់តាមរយៈគ្រូពេទ្យឯកទេសកុមារ ឬ អ្នកផ្តល់វ៉ាក់សាំង។ អ្នកក៏អាចបង្កើតគណនីគ្រួសារនៅលើ www.MyIRMobile.com (ជាភាសាអង់គ្លេសតែប៉ុណ្ណោះ) ហើយបន្ថែមប្រវត្តិរបស់កូនអ្នកទៅក្នុងប្រវត្តិផ្ទាល់ខ្លួនរបស់អ្នក។

**តើនឹងមានអ្វីកើតឡើង បើសិនជាខ្ញុំបានទទួលការចាក់វ៉ាក់សាំងនៅក្រៅរដ្ឋវ៉ាស៊ីនតោន?**
ប្រសិនបើអ្នកមិនបានទទួលការចាក់វ៉ាក់សាំងនៅក្នុងរដ្ឋវ៉ាស៊ីនតោនទេ កំណត់ត្រាចាក់វ៉ាក់សាំងរបស់អ្នកអាចនឹងមិនឆ្លុះបញ្ចាំងឲ្យឃើញនៅលើ MyIR Mobileនោះទេ។ សូមប្រាកដថាអ្នកមានភស្តុតាងបញ្ជាក់ផ្សេងទៀតអំពីការចាក់វ៉ាក់សាំង COVID-19 ដូចជាប័ណ្ណ Vax របស់ CDC ឬកំណត់ត្រាផ្សេងផ្ទាត់ផ្សេងទៀត តាមរយៈអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក។

ប្រសិនបើអ្នកមិនបានទទួលការចាក់វ៉ាក់សាំងនៅក្នុងសហរដ្ឋអាមេរិកទេ សូមយកមកជាមួយនូវភស្តុតាងបញ្ជាក់ផ្លូវការអំពីការចាក់វ៉ាក់សាំងពីប្រទេសចាក់វ៉ាក់សាំងរបស់អ្នក។

**តើខ្ញុំទទួលបានរាល់កំណត់ត្រាចាក់វ៉ាក់សាំងរបស់ខ្ញុំទាំងអស់សម្រាប់ខ្លួនខ្ញុំនិងគ្រួសាររបស់ខ្ញុំ (មិនត្រឹមតែការចាក់វ៉ាក់សាំង COVID-19 ប៉ុណ្ណោះទេ) យ៉ាងដូចម្តេច?**
សម្រាប់បញ្ជីរាយនាមទាំងស្រុងអំពីកំណត់ត្រាវ៉ាក់សាំងសម្រាប់អ្នកនិងសមាជិកគ្រួសារអ្នក អ្នកអាចទាក់ទងទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាពបឋមរបស់អ្នក ឬបង្កើតគណនីមួយតាមរយៈ wa.MyIR.net (ភាសាអង់គ្លេសតែប៉ុណ្ណោះ)។

សម្រាប់ជំនួយភាសា ឬជំនួយផ្សេងៗទៀតក្នុងការទទួលបានកំណត់ត្រារបស់អ្នក អ្នកអាចទូរសព្ទទៅ Office of Immunization and Child Profile (ការិយាល័យនៃការចាក់ថ្នាំបង្ការនិងប្រវត្តិកុមារ)រដ្ឋវ៉ាស៊ីនតោន ក្នុងម៉ោងធ្វើការតាមរយៈលេខ 360-236-3595 ឬទាក់ទងតាមអ៊ីមែលតាមរយៈ waiisrecords@doh.wa.gov។

DOH 348-819 June 2021

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ1-800-525-0127។ អតិថិជនស្ដាប់មិនឮ ឬស្ដាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay (មានជាភាសាអង់គ្លេស)) ឬអ៊ីម៉ែល civil.rights@doh.wa.gov។